# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី០៦  ខែកញ្ញា   ឆ្នាំ២០១៣

## ជប៉ុនផ្តល់ ៧៩១,៧២០ ដុល្លារអាមេរិកដើម្បីបង្កើនប្រសិទ្ធភាពបោស សម្អាតមីន ក្នុងខេត្តបាត់ដំបង (ឆ្នាំ២០១៣)



ក្រោមគ្រោងការណ៍នៃ ជំនួយឧបត្ថម្ភឥតសំណង សម្រាប់គម្រោង របស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន  រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន៦៤,៩២១,០៤០យ៉េន(ប្រមាណជា៧៩១,៧២០ដុល្លារអាមេរិក)  ដល់អង្គការសកម្មភាពកំចាត់មីនជប៉ុន(JMAS)។  កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកតាកាគូវ៉ា ហ្វ៊ូមីតូហ្ស៊ី ប្រធានតំណាងអង្គការ JMAS ដើម្បីអនុវត្តគម្រោងបង្កើនប្រសិទ្ធភាពបោសសម្អាតមីននៅខេត្តបាត់ដំបង (ឆ្នាំ២០១៣)។



គម្រោងនេះគឺដើម្បីផ្តល់ធនធានសម្រាប់ក្រុមប្រតិបត្តិការបោសសម្អាតមីន២ក្រុម  ព្រមទាំងផ្តល់ជំនួយបច្ចេកទេសពីទីប្រឹក្សារបស់JMASនៅភូមិភ្នាវ ភូមិរស្មីសង្ហារ ភូមិស្វាយសរ និងភូមិតាគ្រក់ ក្នុងស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង។ យើងរំពឹងថា  គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ៦,៧០០នាក់ដោយកាត់បន្ថយការគំរាមកំហែងពីគ្រាប់មីន  និង ឈានទៅអភិវឌ្ឍន៍សហគមន៍នៅពេលដែលតំបន់នោះត្រូវបានរំដោះមីនរួច។  ជាងនេះទៅទៀត  ជាផ្នែកមួយនៃការផ្ទេរបច្ចេកទេស JMASគ្រោងនឹងប្រើប្រាស់ ″សៀវភៅណែនាំអំពីប្រតិបត្តិការ″ ដែលរៀបរៀងដោយ JMAS និង CMAC ក្នុងប្រតិបត្តិការគម្រោងលើកមុនហើយដែលថ្នាក់ដឹកនាំរបស់CMACនឹងប្រើប្រាស់នៅទីលានបោសសម្អាតមីនដើម្បីឲ្យប្រតិបត្តិការប្រព្រឹត្តិទៅប្រកបដោយសុវត្ថិភាព និងកាន់តែមានប្រសិទ្ធភាព។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង១៨.៦លាន ដុល្លាអាមេរិកដល់គម្រោងចំនួន ៧២គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសំអាតមីន។ គម្រោងនេះគឺជាគម្រោងទី២តាមរយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៣របស់ជប៉ុន(មេសា២០១២ដល់មិនា២០១៣)។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*